# សេចក្តីថ្លែងការណ៍រួម

## ស្នើសុំដោះលែង និងទម្លាក់ចោលបទចោទ
## លើអ្នកការពារសិទ្ធិមនុស្ស និងសកម្មជនការពារបរិស្ថាន
## លោក កើត សារ៉ាយ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤

ក្រុមយុវជន សហគមន៍មូលដ្ឋាន សហជីព សមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាតិ មានការសោកស្តាយជាខ្លាំងចំពោះការចាប់ឃុំខ្លួនលោក កើត សារ៉ាយ ប្រធានសមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ (KSILA) និងជាអ្នកការពារសិទ្ធិមនុស្សដ៏សកម្មមួយរូប។

សូមបញ្ជាក់ថាលោក កើត សារ៉ាយ ត្រូវបានមន្ត្រីនគរបាលរាជធានីភ្នំពេញចូលចាប់ខ្លួន ខណៈលោកកំពុងបំពេញការងារនៅការិយាល័យ រួចបញ្ជូនទៅកាន់ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញវេលា ម៉ោង១៥.៤៥នាទីកាលពីថ្ងៃទី០៥ ខែមេសា ឆ្នាំ២០២៤ តាមដីកាបញ្ជាឱ្យចូលខ្លួនរបស់លោក សេង ហៀង ព្រះរាជអាជ្ញារងនៃអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ចុះថ្ងៃទី៥ ខែមេសា ឆ្នាំ២០២៤ ដែលក្នុងដីកានោះបានត្រឹមបញ្ជាក់ថាពាក់ព័ន្ធករណី **ញុះញង់បង្កឱ្យមានភាពវឹកវរធ្ងន់ធ្ងរដល់សន្តិសុខសង្គម។** ការចាប់ខ្លួននេះធ្វើឡើងដោយមិនបានផ្តល់ព័ត៌មានជាក់លាក់ អំពីបទចោទប្រកាន់ទៅកាន់លោកកើត សារ៉ាយ និងក្រុមគ្រួសាររបស់ លោកឡើយ។ យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អយ្យការអមសារដំបូងរាជធានីភ្នំពេញ បានប្រកាសថាលោក កើត សារ៉ាយ ក៏បានប្រឈមនឹងការចោទប្រកាន់បន្ថែមពីបទ **មិនរាងចាលក្នុងបទមជ្ឈឹមបន្ទាប់ពីផ្តន្ទាទោសបទមជ្ឈឹម** ព្រមទាំងបានឃុំខ្លួនជាបណ្តោះអាសន្ននៅពន្ធនាគារព្រៃសនៅរសៀលថ្ងៃទី៧ ខែមេសា ឆ្នាំ២០២៤។

ការឃាត់ខ្លួន និងឃុំខ្លួន លោកកើត សារ៉ាយ  គឺជាការបន្តបិទសំឡេង និងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងបង្ក្រាបទៅលើសកម្មជនសិទ្ធិមនុស្ស និងបរិស្ថាន ដែលនេះជាការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើសិទ្ធិសេរីភាពជាមូលដ្ឋានដែលធានាដោយរដ្ឋធម្មនុញ្ញកម្ពុជា។ ការផ្តល់បទសម្ភាសន៍ដល់សារព័ត៌មាន ជាពិសេសការបញ្ចេញមតិពីវិវាទដីធ្លីក្នុងខេត្តព្រះវិហារ គឺជាការខ្វាយខ្វល់ចំពោះបញ្ហាជីវភាពរបស់ពលរដ្ឋ និងពាំនាំក្តីកង្វល់របស់ពួកគេដើម្បីជំរុញឱ្យអាជ្ញាធរដោះស្រាយបញ្ហាដល់ពលរដ្ឋប៉ុណ្ណោះ។ ការបញ្ចេញមតិរបស់លោកគួរត្រូវបានចាត់ទុកថាជាការជួយដល់អាជ្ញាធរក្នុងការដោះស្រាយបញ្ហាជាជាងការញុះញង់។ បន្ថែមលើសពីនេះការចាប់ខ្លួនសកម្មជននៅកៀកថ្ងៃនៃការប្រារព្ធពិធីបុណ្យចូលឆ្នាំប្រពៃណីជាតិ គឺរឹតតែធ្វើឱ្យលោកបាត់បង់នូវសិទ្ធិសេរីភាពជួបជុំសមាជិកក្រុមគ្រួសារអំឡុងពេលបុណ្យចូលឆ្នាំប្រពៃណីជាតិខ្មែរនេះ ដែលពលរដ្ឋខ្មែរគ្រប់រូបចាត់ទុកថាជាឱកាសដ៏វិសេសវិសាលក្នុងការជួបជុំគ្រួសារផងដែរ។

សូមរំលឹកថាកាលពីថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០២០ លោក កើត សារ៉ាយ ដែលជាអតីតព្រះសង្ឃក៏ធ្លាប់ត្រូវបានអាជ្ញាធរចាប់ព្រះកាយផ្សឹក និងកាត់ទោសរួមជាមួយយុវជនជាអតីតសកម្មជនសង្គមចំនួន៨នាក់ផ្សេងទៀតដោយសារតែបានធ្វើការតស៊ូមតិស្នើសុំឱ្យដោះលែងថ្នាក់ដឹកនាំសហជីពលោករ៉ុង ឈុន។គ្រានោះលោកត្រូវបានតុលាការរាជធានីភ្នំពេញចោទប្រកាន់ពីបទញុះញង់តាមបញ្ញត្តិមាត្រា៤៩៤ និងមាត្រា៤៩៥នៃក្រមព្រហ្មទណ្ឌ និងកាត់ទោសឱ្យជាប់ពន្ធនាគារ២០ខែ ប៉ុន្តែបន្ទាប់ពីអនុវត្តទោសបានមួយឆ្នាំបួនខែ ទោសនេះក៏ត្រូវបានព្យួររយៈពេល៦ខែ។ លោកត្រូវបានដោះលែងឱ្យមានសេរីភាពឡើងវិញនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២១។

យើងទាំងអស់គ្នាជាក្រុមយុវជន សហគមន៍ សហជីព សមាគម អង្គការសង្គមស៊ីវិលជាតិសូមអំពាវនាវដល់សាលាដំបូងរាជធានីភ្នំពេញមេត្តាទម្លាក់ចោលបទចោទ និងដោះលែងសកម្មជនសិទ្ធិមនុស្ស និងបរិស្ថានលោកកើតសារ៉ាយជាបន្ទាន់និងឥតលក្ខខណ្ឌ និងបើកចំហសេរីភាពក្នុងការបញ្ចេញមតិ ឱ្យបានពេញលេញដល់ពលរដ្ឋ ដែលខ្វល់ខ្វាយពីបញ្ហាសង្គម។ យើងខ្ញុំទាំងអស់គ្នាសូមអំពាវនាវដល់អាជ្ញាធររដ្ឋ មេត្តាគោរពនិងបើកចំហលំហសេរីភាពអង្គការសមាគម គោរពសិទ្ធិមនុស្ស គោរពសិទ្ធិអ្នកការពារសិទ្ធិមនុស្ស និងលើកកម្ពស់សេរីភាពបញ្ចេញមតិដើម្បីចូលរួមស្ថាបនាប្រទេសជាតិ៕

**សេចក្ដីថ្លែងការណ៍នេះគាំទ្រដោយៈ**

| | | |
|---|---|---|
| 1. | សមាគមសម្ពន្ធនិស្សិតបញ្ញវន្តខ្មែរ | KSILA |
| 2. | សមាគមប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រព័ន្ធ | IDEA |
| 3. | អង្គការភាពជាដៃគូដើម្បីបរិស្ថាន និងការអភិវឌ្ឍ | PED |
| 4. | សមាគមបណ្ដាញយុវជនកម្ពុជា | CYN |
| 5. | សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ | LICADHO |
| 6. | សមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា | ADHOC |
| 7. | មជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និង សិទ្ធិមនុស្ស | CENTRAL |
| 8. | សហព័ន្ធសហជីព កម្មករចំណីអាហារ និងសេវាកម្ម កម្ពុជា | CFSWF |
| 9. | គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា | COMFREL |
| 10. | សហព័ន្ធសហជីពកម្មករនយោជិតវិស័យទេសចរណ៍កម្ពុជា | CTWUF |
| 11. | សហព័ន្ធសហជីពឯករាជ្យ | INTUFE |
| 12. | មជ្ឈមណ្ឌលប្រជាពលរដ្ឋដើម្បីអភិវឌ្ឍន៍និងសន្តិភាព | PDP-Center |
| 13. | អង្គការអភិវឌ្ឍន៍ធនធានយុវជន | YRDP |
| 14. | អង្គការសម្ព័ន្ធដើម្បីសុចរិតភាព និងគណនេយ្យភាពសង្គម | CISA |
| 15. | វិទ្យាស្ថានប្រជាធិបតេយ្យកម្ពុជា | CID |
| 16. | មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា | CCHR |
| 17. | សម្ព័ន្ធសហជីពកម្ពុជា | CATU |

18. សហព័ន្ធសហជីពសេរីឯករាជ្យ FUFI
19. អង្គការអប់រំយុវជនដើម្បីអភិវឌ្ឍន៍ និងសន្តិភាព YEDP
20. សមាគមន៍កម្មករកម្ពុជាសេដ្ឋកិច្ចក្រៅប្រព័ន្ធ CIWA
21. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា
ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទំរង់នៃការរើសអើងលើស្ត្រីភេទ NGO-CEDAW
22. សហភាពពហុវិស័យកម្ពុជា CCC
23. សហពន្ធ័សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា FTUWKC
24. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា
25. ចលនាមាតាធម្មជាតិ
26. សហគមន៍ព្រៃឡង់ (ខេត្តស្ទឹងត្រែង)
27. សហគមន៍ធនធានព្រៃឈើស្ទឹងខ្សាច់ស (កំពង់ឆ្នាំង)
28. សហគមន៍ព្រៃឈើត្រពាំងចាន់ (កំពង់ឆ្នាំង)
29. សហគមន៍ព្រៃឡង់ (ព្រះវិហារ)
30. សហគមន៍ត្រពាំងជោ (កំពង់ស្ពឺ)
31. សហគមន៍រស្មីសាមគ្គី (កំពង់ស្ពឺ)
32. សហគមន៍អមលាំង (កំពង់ស្ពឺ)
33. សហគមន៍ដីធ្លី ១៩៧ (កោះកុង)
34. សហគមន៍ដីធ្លីជីខក្រោម (កោះកុង)
35. សហគមន៍ព្រៃឈើពេជ្រចង្វាល្អធើត (កំពង់ឆ្នាំង)
36. សហគមន៍ដីធ្លីស្រែប្រាំង (ត្បូងឃ្មុំ)
37. សហគមន៍ទ្រទ្រង់ធម្មជាតិ (ពោធិ៍សាត់)
38. សហគមន៍ភ្នំក្រោម (សៀមរាប)
39. សហគមន៍ដីធ្លីតានី (សៀមរាប)
40. សហគមន៍ដីធ្លីខេត្តប៉ៃលិន
41. សហគមន៍បឹងប្រាំ (បាត់ដំបង)
42. សហគមន៍ដីធ្លីអណ្តូងត្របែក (ស្វាយរៀង)
43. សហគមន៍សាមគ្គីចេកមាស (ស្វាយរៀង)
44. សហគមន៍ព្រៃឡង់ (ក្រចេះ)
45. សហគមន៍ព្រៃឡង់ (កំពង់ធំ)
46. សហគមន៍ត្នោតជុំ (ពោធិ៍សាត់)
47. សហគមន៍ជនជាតិដើមភាគតិចកួយ ខេត្តព្រះវិហារ
48. សហគមន៍ដីធ្លីភូមិសិលាខ្មែរ (បន្ទាយមានជ័យ)
49. សហគមន៍ ព្រៃឈើរតនៈរុក្ខា (ឧត្តរមានជ័យ)

50. សហគមន៍សាមគ្គីមាសហែក (ស្វាយរៀង)
51. សហគមន៍សង្កែពីរមានរិទ្ធិ (ព្រះវិហារ)
52. សហគមន៍សំរោងត្បូង (ភ្នំពេញ)
53. សហគមន៍ទន្លូង (ត្បូងឃ្មុំ)
54. សហគមន៍មានជ័យ (ស្វាយរៀង)